# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះ សាកលវិទ្យាល័យអាស៊ាន

## ទៅជា សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យអាស៊ាន
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៣៥៧៩ អយក.ឧស ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១ :** ទទួលស្គាល់ការប្ដូរឈ្មោះ **សាកលវិទ្យាល័យអាស៊ាន** ទៅជា **សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ** " **Phnom Penh International University** " ហៅកាត់ជាភាសាខ្មែរ " **ស.ភ.ព.អ** " និងហៅកាត់ជាភាសាអង់គ្លេស " **PPIU** " ។ សាកលវិទ្យាល័យនេះ មានទីតាំងគោលស្ថិតនៅ អាគារលេខ ១ ផ្លូវលេខ ១៣៩ សង្កាត់ វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានភារកិច្ច :

- បណ្ដុះបណ្ដាលអ្នកជំនាញឯកទេស ឧត្ដមសិក្សាគ្រប់កម្រិត ស្របតាមបេសកកម្មរបស់ សាកលវិទ្យាល័យ ។
- បង្កើនសមត្ថភាពមុខជំនាញបច្ចេកទេសដល់គ្រូបង្រៀន សាស្ត្រាចារ្យ សម្រាប់សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- រៀបចំកម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារការងារ ស្តង់ដារអន្តរជាតិ និងបទដ្ឋានរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។
- សិក្សាស្រាវជ្រាវខ្លឹមសារនៃការសិក្សា វិធីសាស្ត្របង្រៀន និងចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រជាភាសាជាតិ និងភាសាបរទេស ឱ្យបានសមស្របសម្រាប់ប្រើប្រាស់ ។
- រៀបចំ និងដំណើរការជ្រើសរើសនិស្សិតឱ្យចូលរៀន ប្រឡងចេញ និងស្វ័យវាយតម្លៃលើការសិក្សាឱ្យបានត្រឹមត្រូវ តាមគោលការណ៍ និងប្រកបដោយតម្លាភាព ។
- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រតាមឯកទេសរបស់សាកលវិទ្យាល័យ ។
- កសាងផែនការអភិវឌ្ឍសម្រាប់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- គ្រប់គ្រង និយោជិក កម្មករ និស្សិត សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានាក្នុងគោលបំណងធ្វើឱ្យកាន់តែល្អប្រសើរឡើង នូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ ។

**មាត្រា ៤ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ធ្វើការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈសិក្សារយៈពេលក្រោម ២ឆ្នាំ ថ្នាក់បរិញ្ញាបត្ររង សិក្សារយៈពេល ២ឆ្នាំ ថ្នាក់បរិញ្ញាបត្រ សិក្សារយៈពេល ៤ឆ្នាំ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សាស្រាវជ្រាវ រយៈពេល ២ឆ្នាំ និងថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវ រយៈពេល ៣ឆ្នាំ ជាមធ្យម ដែលរចនាសម្ព័ន្ធសិក្សាត្រូវបានរៀបចំឱ្យមាន មហាវិទ្យាល័យ ចំនួន ០៤ និងមជ្ឈមណ្ឌលថ្នាក់ជំនាញវិជ្ជាជីវៈ ០១ គឺ :

- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និងទេសចរណ៍
- មហាវិទ្យាល័យ នីតិសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យ វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា
- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ
- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលថ្នាក់វិជ្ជាជីវៈរយៈពេលខ្លី

ទៅអនាគត សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ អាចប្ដូរឈ្មោះ ប្ដូរទីតាំង ឬការធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានឧត្ដមសិក្សាបរទេស ការបង្កើតមហាវិទ្យាល័យ ឬសាខា ឬឯកទេស ឬប្រភេទបណ្ដុះបណ្ដាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពី ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលរបស់ ស.ភ.ព.អ និងដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨ :** សាកលវិទ្យាធិការមានភារកិច្ច :

- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រង សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- រៀបចំផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- ទទួលបន្ទុកអនុវត្តបទដ្ឋានទាំងឡាយ របស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដែលពាក់ព័ន្ធទៅនឹងការងារបណ្តុះបណ្តាល ។
- ធ្វើរបាយការណ៍គ្រប់គ្រងប្រចាំឆមាស ប្រចាំឆ្នាំ និងសកម្មភាពផ្សេងៗទៀត ជូនក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចដល់អង្គភាពនានាក្រោមឱវាទ ។
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក ។
- កំណត់បទបញ្ជាផ្ទៃក្នុង នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ។
- ត្រូវធានាឱ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ។
- ជាតំណាងរបស់សាកលវិទ្យាល័យ ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

**មាត្រា ៩ :** និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់ សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ហើយមានការទទួលស្គាល់ពី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្តតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៥ ខែ ១៧ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ